# ទីកន្លែងចិញ្ចឹមក្រួច



ក្រួចត្រូវការទីកន្លែងតូច យើងមិនចាំបាច់ត្រូវមានទីធំដូចជាមាន់ទាឡើយ ទីទំហំចំនួនមួយម៉ែត្រក្រឡាអាចឱ្យយើងដាក់ក្រួចបានចំនួន ១០០ ក្បាល ។ ដូច្នេះ យើងត្រូវជ្រើសរើសទីកន្លែងណាមួយដែលសមស្របបំផុត នៅក្នុងបរិវេណដីរបស់យើង ។

ទីទួល ទីស្រឡះ មានខ្យល់ចេញចូលបានល្អ មានពន្លឺថ្ងៃចូលដល់និងមានប្រភពទឹកស្អាតសម្រាប់ផ្គត់ផ្គង់ឱ្យវា ។ ទំហំដីដែលយើងត្រូវការ ទាក់ទងច្រើនទៅនិងចំនួនក្រួចដែលយើងត្រៀមចិញ្ចឹម បើយើងមានបំណងធ្វើជាកន្លែងចិញ្ចឹមក្នុងទ្រង់ទ្រាយធំ យើងចាំបាច់ត្រូវមានទីកន្លែងមួយធំគួរសម និងនៅដាច់ឆ្ងាយពីគេ ។

បើសិនជាយើងត្រៀមចិញ្ចឹមដើម្បីផ្គត់ផ្គង់សាច់សម្រាប់បរិភោគក្នុងគ្រួសារនិងលក់ចែកចាយឱ្យអ្នកក្បែរខាងក្នុងភូមិទេនោះ យើងមិនចាំបាច់ត្រូវមានទីធមពេកនោះឡើយត្រឹមតែ បីម៉ែត្រគុណនិងប្រាំម៉ែត្រគឺល្មមគ្រប់គ្រាន់សម្រាប់ចិញ្ចឹមក្រួចបានជាង ១០០០ក្បាលដែរ ។

## រោងសម្រាប់ចិញ្ចឹមក្រួច



រោងសម្រាប់ចិញ្ចឹមក្រួច អាចសង់ឡើងដោយវិធីណាមួយក៏បាន យើងអាចចិញ្ចឹមវានៅលើដីផ្ទាល់ឬអាចធ្វើជាកម្រាលក្រាលដោយសំណាញ់ភ្នែកក្រួចទៅតាមលទ្ធភាពដែលយើងមាន ។

ដំបូលគួរប្រក់ស្លឹកឬស្បូវដើម្បីកាត់បន្ថយកំដៅ បើប្រើស័ង្កសីសម្រាប់ប្រក់ គួរតែ ធ្វើដំបូលនោះឱ្យខ្ពស់បន្តិច ដើម្បីកាត់បន្ថយកំដៅនៅខែប្រាំង ។

បើយើងសម្រេចចិត្តយកការចិញ្ចឹមនៅលើដី ផ្ទៃដីក្នុងរោងទាំងមូលត្រូវរៀបចំធ្វើឱ្យបានស្អាត បន្ទាប់មកត្រូវបាចកំបោរស ដើម្បីសម្លាប់មេរោគ បន្ទាប់ពីនោះ យើងត្រូវដាក់អង្កាមឬអាចម៍រណា ក្រាលលើដី បើគ្មានវត្ថុទាំងពីរនេះទេ យើងអាចប្រើចំបើងកាត់ខ្លីៗដាក់ក្រាលក៏បាន កម្រាលនេះធ្វើ ដើម្បីកាត់បន្ថយសំណើមពីលាមករបស់វា និងដើម្បីកាត់បន្ថយ ការសំអាតទ្រុងរបស់វា, ដោយយើង គ្រាន់តែកើបប្រមូលយកកម្រាលនោះចេញ រួចដាក់កម្រាលថ្មីជាជំនួសវិញជាការស្រេច ។

ជញ្ជាំងរបស់ទ្រុង យើងអាចធ្វើពីសំណាញ់យ៉ាំងការ ឬ សំណាញ់ភ្នែកក្រួចក៏បានបើមានលទ្ធភាព តែបើមិនមានលទ្ធភាពទេ យើងអាចត្បាញជាព្រួលដើម្បីធ្វើជាជញ្ជាំងឱ្យវាក៏បាន ។

នៅក្នុងទ្រុងនេះ យើងចាំបាច់ត្រូវសំអាតវាឱ្យស្អាតជានិច្ច មិនត្រូវឱ្យសត្វឆ្កែឆ្មាកណ្តុរចូលបានឡើយ ព្រោះសត្វទាំងនេះវាអាចជាអ្នកចម្លងមេរោគទៅសត្វក្រួចបាន ។

ទ្រុងមួយចំនួនផ្សេងត្រូវធ្វើជាចាំបាច់ដើម្បីដាក់កូនក្រួចដែលនៅតូចឬទើបភ្ញាស់ រូបរាងរបស់ទ្រុងមិន សំខាន់ទេ តែត្រូវធ្វើគម្របដើម្បីបើកបិទពីខាងលើ គម្របទ្រុងនេះត្រូវធ្វើប្រហោងដើម្បីយើង អាចដាក់ចង្កៀងដើម្បី

កំដៅកូនក្រួចនៅពេលវានៅតូចដើម្បីផ្តល់កំដៅឱ្យវា ។ មួយវិញទៀតនោះ ចង្កៀងនេះ អាចជួយ បណ្តេញមូស និងសត្វល្អិតនានាកុំឱ្យមកទិចឬខាំកូនក្រួចនោះផងដែរ ។

- ក្រួចជាសត្វដែលឈ្មុះជម្ងឺ យើងមិនចាំបាច់ចាក់វ៉ាក់សាំងឱ្យវាទេ តែត្រូវមានការថែទាំ ដិតដល់
- ចំណីមិនត្រូវឱ្យខ្វះឡើយ បើពុំនោះទេ កូនដែលញាស់មកវាទន់ជើង នេះគឺបណ្តាលមកពី ការឱ្យចំណីដល់មេវាមិនបានគ្រប់គ្រាន់ ។

(ដកស្រង់ចេញពី ខេមបូឌាអេចប្រេសញូស៍)